**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សមាគមទេសចរណ៍កម្ពុជា**
**លេខ ៖.០០១-០៩/២៦ សជណ**

# សេចក្តីជូនដំណឹង
# ស្តីពីការបង់វិភាគទានសមាជិកភាព
# សមាគមទេសចរណ៍កម្ពុជាសម្រាប់ឆ្នាំ២០២៦

**យោង៖** -កិច្ចប្រជុំថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥ របស់គណៈកម្មការប្រតិបត្តិសមាគមទេសចរណ៍កម្ពុជា
-កិច្ចប្រជុំបូកសរុបប្រចាំឆ្នាំថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៥ របស់សមាគមទេសចរណ៍កម្ពុជា
-កិច្ចប្រជុំថ្ងៃទី២០ ខែមករា ឆ្នាំ២០២៦ របស់គណៈកម្មការប្រតិបត្តិសមាគមទេសចរណ៍កម្ពុជា

**សមាគមទេសចរណ៍កម្ពុជា** (CATA) មានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី** ជាថ្នាក់ដឹកនាំ និងសមាជិកសមាគមទេសចរណ៍កម្ពុជា មេត្តាជ្រាបថា **សមាគមបានរៀបចំ**កិច្ចប្រជុំនឹងបានអនុម័តក្នុងការបង្កើតអនុគណៈកម្មការទំនាក់ទំនងសមាជិក ដើម្បីពង្រឹងការចូលរួម កែលម្អទំនាក់ទំនង និងគាំទ្រដល់កំណើនសមាជិកភាព ដោយផ្តោតលើភារកិច្ចសំខាន់ៗរួមមាន ការជ្រើសរើសសមាជិកថ្មី ការកែសម្រួលនីតិវិធីសមាជិកភាព ការគ្រប់គ្រងសមាជិកអសកម្ម និងការរៀបចំព្រឹត្តិការណ៍បណ្តាញទំនាក់ទំនង ដើម្បីបង្កើនការចូលរួមយ៉ាងសកម្ម ប្រកបដោយទំនុកចិត្តស្មារតីទទួលខុសត្រូវ សាមគ្គីភាព និងឯកភាពគ្នានឹងដើម្បីសម្រេចបាននូវផែនការរួម និរន្តរភាពកាន់តែប្រសើរ រួមទាំងទទួលបានអត្ថប្រយោជន៍ ព័ត៌មានថ្មីៗ ការចូលរួមក្នុងព្រឹត្តិការណ៍ ឱកាសបណ្តុះបណ្តាលផ្សេងៗ ជាពិសេសទទួលបានសិទ្ធិពេញលេញ ខណៈពេលដែលដៃគូ និងសាជីវកម្មទទួលបានសិទ្ធិផ្សព្វផ្សាយម៉ាកយីហោ និងភាពជាដៃគូ។

ក្នុងន័យនេះដើម្បីស្របតាមផែនការអភិវឌ្ឍន៍សមាជិកភាពរបស់សមាគមទេសចរណ៍កម្ពុជា ដោយកំណត់នូវប្រភេទសមាជិកភាពចំនួនបួន(៤) មានដូចខាងក្រោម៖

| ល.រ | ប្រភេទសមាជិក | វិភាគទាន | ផ្សេងៗ |
|---|---|---|---|
| ១ | សមាជិកធម្មតា<br>Ordinary Member | ២០០ដុល្លារ/ឆ្នាំ +៥០ដុល្លារថ្លៃរដ្ឋបាល(សម្រាប់តែឆ្នាំដំបូង) | ផ្តល់ជូនតែប្រតិបត្តិករទេសចរណ៍ដែលមានអាជ្ញាបណ្ណទេសចរណ៍ជាទីភ្នាក់ងារទេសចរណ៍ ឬការីទេសចរណ៍ (TO & TA)<br>*សិទ្ធចូលរួមក្នុងការបោះឆ្នោត |
| ២ | សមាជិកកិត្តិយស<br>Honorary Member | ១០០ដុល្លារ/ឆ្នាំ | - ផ្តល់ជូនសម្រាប់ករណីចាំបាច់តែប៉ុណ្ណោះ<br>*ពុំមានសិទ្ធចូលរួមក្នុងការបោះឆ្នោត |

| | | | |
|---|---|---|---|
| ៣ | សមាជិកដៃគូ<br>Partner Member | ៥០០ដុល្លារ/ឆ្នាំ +៥០ដុល្លារផ្នែករដ្ឋបាល(សម្រាប់តែឆ្នាំដំបូង) | - សម្រាប់គ្រប់ប្រភេទអាជីវកម្ម និងសេវាកម្មទាំងអស់ដែលមិនមែនជាទីភ្នាក់ងារទេសចរណ៍ ឬការីទេសចរណ៍ (TO & TA)<br>*ពុំមានសិទ្ធចូលរួមក្នុងការបោះឆ្នោត |
| ៤ | សមាជិកសាជីវកម្ម<br>Corporate Member | អាស្រ័យលើកិច្ចសហការនានា | - សម្រាប់គ្រប់ប្រភេទអាជីវកម្ម និងសេវាកម្មទាំងអស់ដែលមិនមែនជាទីភ្នាក់ងារទេសចរណ៍ ឬការីទេសចរណ៍ (TO & TA)<br>*ពុំមានសិទ្ធចូលរួមក្នុងការបោះឆ្នោត |

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី** ជាថ្នាក់ដឹកនាំ និងសមាជិកសមាគមទេសចរណ៍កម្ពុជា ទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

*__សម្គាល់៖ សម្រាប់ការចូលរួមបង់វិភាគទានសមាជិកភាពមុនខែមេសា ឆ្នាំ២០២៦ នឹងទទួលបានការបញ្ចុះតម្លៃ ១០% ។__

ថ្ងៃពុធ ៣កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩
រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែមករា ឆ្នាំ២០២៦
**សមាគមទេសចរណ៍កម្ពុជា**